អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ហេតុអ្វីបានជាបាល់លោត?**

**ចិត្តចលភាព៖** បំណិនចលនាធំ៖ ការហ្វឹកហាត់បង្កើនកម្លាំង និងការសម្របសម្រួល នៃចលានាសាច់ដុំធំ និងតូច។

**វិទ្យាសាស្ត្រ៖** ការរស់នៅប្រចាំថ្ងៃ៖ ការស្វែងយល់ដោយការសង្កេត។

**បុរេគណិត៖** រង្វាស់រង្វាល់៖ បញ្ញបត្តិស្ដីពីរង្វាស់រង្វាល់៖ បញ្ញត្តិនៃរូបរាង និងលំហ។

**គោលបំណង** ៖

**ចិត្តចលភាព៖** ប្រាប់ពីរបៀបដើរ រត់ លូន លោត ចុះនិងឡើង បោះ តោង ឡើង គប់  បង្វិលខ្លួន រុញ និងច្រាន ទៅតាមគោលដៅបានចម្ងាយដែលបានកំណត់។

**វិទ្យាសាស្ត្រ៖** ប្រាប់បានពីការពិសោធន៍និងស្វែងយល់ដោយប្រើសម្ភារផ្សេងៗក្នុងការលេង ដូចជា៖ លិច អណ្ដែត ជ្រាបទឹក មិនជ្រាបទឹក វត្ថុរលាយនិងមិនរលាយ ការលាយពណ៌ បណ្ដុះគ្រាប់ធញ្ញជាតិ ខ្យល់ជាដើម…។

**បុរេគណិត៖** ប្រាប់បានពីបញ្ញត្តិ ខ្ពស់និងទាប វែងនិងខ្លី ធ្ងន់និងស្រាល ច្រើននិងតិច មាន និងមិនមាន និងពេញនិងកន្លះ។

ប្រាប់បានពីរូបរាងសាមញ្ញពីធរណីមាត្រដូចជា៖ រូបរាងការេ ត្រីកោណ រង្វង់ និងចតុកោណកែងជាដើម…។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ មានសម្ភារជាច្រើនផ្សេងៗគ្នា ដូចជាបាល់និងសម្ភារផ្សេងៗមួយចំនួនទៀត

**កម្រិតសិក្សា** ៖ មធ្យម និង ខ្ពស់

**ការរៀបចំ** ៖ ទីកន្លែងនិងសម្ភារសម្រាប់លេង

**សេចក្ដីណែនាំ៖**

1. ដំបូងប្រាប់ក្មេងៗថា កូនៗចង់ដឹងទេថា ហេតុអ្វីបានជាបាល់វាលោត? ហេតុអ្វីមានបាល់ខ្លះលោតខ្ពស់និងបាល់ខ្លះលោតមិនសូវខ្ពស់។
2. បន្តិចទៀតយើងនឹងទៅលេងពិសោធន៍ថា ហេតុអ្វីបានជាបាល់លោតខ្ពស់ និងមិនសូវខ្ពស់។
3. ដំបូងប្រាប់ពីរបៀបនៃការធ្វើការពិសោធន៍ទៅកាន់ពួកគេជាមុនសិន៖

ការពិសោធន៍ទី១៖

- ប្រើបាល់ពីរប្រភេទផ្សេងគ្នា
- សួរក្មេងៗថាតើមួយណាលោតខ្ពស់ជាង? ហេតុអ្វី?
- ដាក់បាល់ទាំងពីរនៅកម្ពស់ស្មើគ្នា និងត្រូវទម្លាក់លើដី ស្មៅ... (កន្លែងដូចគ្នា)។
- ឱ្យក្មេងៗចាំសង្កេតមើលថា តើបាល់មួយណាលោតខ្ពស់ជាង?
- បន្ទាប់មកប្រាប់ពួកគេពីមូលហេតុអ្វីបានជាបាល់ខ្លះលោតខ្ពស់ និងបាល់ខ្លះលោតមិនសូវខ្ពស់?

ការពិសោធន៍ទី២៖

- ជ្រើសរើសបាល់២ តែបាតខុសៗគ្នា ដូចជា៖ ស្មៅ ក្រណាត់ ក្តារ ឬ ប៊ីតុងជាដើម…។
- ទម្លាក់បាល់ទាំង២ ដែលមានកម្ពស់ស្មើគ្នា តែមានបាតផ្សេងៗគ្នា
- បន្ទាប់មកប្រាប់ឱ្យកុមារសង្កេតថា តើបាល់មួយណាដែលលោតខ្ពស់ជាងគេ រវាងបាតផ្សេងៗនោះ
- ប្រាប់កុមារថាមកពីហេតុអ្វី?

**ហេតុអ្វីបានជាបាល់លោត?**

បាល់មួយត្រូវបានទម្លាក់ ទំនាញផែនដីទាញបាល់ឱ្យធ្លាក់តែម្តង ដូច្នេះការលោតរបស់បាល់នីមួយៗត្រូវទាបទៅៗ រហូតដល់បាល់ឈប់លោតតែម្តង។ កម្លាំងបាល់ប៉ះដីរឹងផ្តល់កម្លាំងស្មើគ្នាលើបាល់មានន័យថា បាល់វាអាចលោតត្រឡប់មកវិញ។ វាកើតឡើងដោយសារតែបាល់បានផលិតឡើងពីការបត់បែនសម្ភារដែលធ្វើឱ្យវាក្លាយជាសំប៉ែតបន្តិត ហើយលាតសន្ធឹងហើយវាត្រឡប់ទៅជារូបរាងដើមវិញ។ប្រសិនបើបាល់ត្រូវបានបង្កើតឡើងដោយវត្ថុទន់ជាងដូចជា ផ្លាស្ទិកវានឹងក្លាយជាសំប៉ែតហើយវានឹងមិនងើបមកវិញនោះទេ តែប្រសិនបើបាល់ត្រូវបានបង្កើតឡើងពីវត្ថុរឹង វានឹងបែកខ្ទេចនៅពេលដែលធ្លាក់មកលើដី។